**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ : ៦២០ ប្រ.ក-វវក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងអាជីវកម្មនិងសេវាកម្ម

## លក់ ជួល ផលិតផលភាពយន្តនិងវីដេអូ

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

-បានឃើញ អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញ អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បភាពយន្តនិងវីដេអូ

-យោងតាមការចាំបាច់របស់ក្រសួង។

## សម្រេច

**ប្រការ ១** : ប្រកាសនេះមានគោលបំណង គ្រប់គ្រងលើអាជីវកម្មនិងសេវាកម្ម លក់ ជួល ផលិតផលភាពយន្តនិងវីដេអូ ជាកាស្សែត វីស៊ីឌីនិងឌីវីឌី ដែលកំពុងធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទ / ទូរសា : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ប្រការ ២** : តែមប្រិ៍និងត្រាទិដ្ឋាការមានលក្ខណៈសម្គាល់ដូចខាងក្រោមៈ

**តែមប្រិ៍ទិដ្ឋាការ** : មានរាងបួនជ្រុងទ្រវែង បណ្តោយប្រវែង ៥០ (ហាសិប)ម.ម និង ទទឹងប្រវែង ២០(ម្ភៃ)ម.ម មានរូបព្រហ្ម ពណ៌ក្រហមស្រអាប់ នៅចំកណ្តាលផ្ទៃ

-មានចារឹកអក្សរ **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** ពណ៌ខៀវនៅផ្នែកខាងលើ

-មាន**លេខទិដ្ឋាការ** នៅផ្នែកកណ្តាល និង

-មានចុះ **កាលបរិច្ឆេទ** ផ្តល់ទិដ្ឋាការនៅផ្នែកខាងក្រោម។

**ត្រាទិដ្ឋាការ** : មានរាងមូលវិជ្ជមាត្រប្រវែង ១៩ (ដប់ប្រាំបួន) ម.ម

-មានរង្វង់មូល ចែកផ្ទៃជាពីរ

-ផ្ទៃខាងក្នុងមានចារឹកអក្សរ ភ.វ និង

-ផ្ទៃខាងក្រៅមានចារឹកអក្សរ គណៈកម្មការត្រួតពិនិត្យ។

គំរូ តែមប្រិ៍និងត្រាទិដ្ឋាការ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៣** : តែមប្រិ៍និងត្រាទិដ្ឋាការ មិនត្រូវបានអនុញ្ញាតឲ្យយកទៅប្រើប្រាស់ខុសពីខ្លឹមសារ ដែលបានកំណត់ក្នុងប្រការ ១ នៃប្រកាសនេះ។

**ប្រការ ៤** : ការក្លែងបន្លំតែមប្រិ៍និងត្រាទិដ្ឋាការ តាមរូបភាពណាមួយ ប្រើទៅលើផលិតផលភាពយន្តនិងវីដេអូ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ៥** : នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធនិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

ហ៊ឹម ឆែម

__កន្លែងទទួល:__

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលារាជធានី ខេត្ត

-ដូចប្រការ ៥

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ